May 3, 2012

# សេចក្តីប្រកាសព័ត៌មាន

ស្តីពីសិក្ខាសាលាថ្នាក់តំបន់នៃតំណាងប្រទេសអាស៊ានចំនួន៨
ក្នុងការពិភាក្សាពីការអនុវត្តល្អរបស់អាជ្ញាធរមូលដ្ឋាន

រាជធានីភ្នំពេញ ថ្ងៃទី៣ ខែឧសភា ឆ្នាំ២០១២ សម្ព័ន្ធភាពជាតិឃុំ សង្កាត់នៃព្រះរាជាណាចក្រកម្ពុជា បានទទួលជាធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចសិក្ខាសាលាថ្នាក់តំបន់ស្តីពី "គម្រោងគាំទ្រវិមជ្ឈការនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ និងគម្រោងភាពជាដៃគូសម្រាប់អភិបាលកិច្ចមូលដ្ឋាននៅអាស៊ីអាគ្នេយ៍ (DELGOSEA) ។ គម្រោងគាំទ្រវិមជ្ឈការនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ត្រូវបានគាំដោយសម្ព័ន្ធទីក្រុងនិងអាជ្ញាធរមូលដ្ឋាន (UCLG) ដោយសហការជាមួយការិយាល័យ UCLG ASPAC ប្រចាំទីក្រុងហ្សាកាតា ប្រទេសឥណ្ឌូនេស៊ី។ DELGOSEA ត្រូវបានគាំទ្រដោយសហគមន៍អឺរ៉ុបនិងមូលនិធិខុនរ៉ាដអាដិនណៅអ៊ែរ នៃប្រទេសអាឡឺម៉ង់ តាមរយៈកិច្ចសហការជាមួយក្រសួងសម្រាប់ការអភិវឌ្ឍនៃប្រទេសអាឡឺម៉ង់។

អ្នកចូលរួមគឺជាតំណាងរដ្ឋាភិបាលមូលដ្ឋានមកពីប្រទេសហ្វីលីពីន ឥណ្ឌូនេស៊ី វៀតណាម កម្ពុជា ថៃឡង់ មាឡេស៊ី មីយ៉ាន់ម៉ា និងឡាវ។ ជាមួយគ្នានោះដែរក៏មានអ្នកចូលរួមពីអង្គការសង្គមស៊ីវិល សាកលវិទ្យាល័យ សមាគមអាជ្ញាធរមូលដ្ឋាន អង្គការអន្តរជាតិនិងប្រព័ន្ធផ្សព្វផ្សាយ។ សិក្ខាសាលាក៏មានការចូលរួមពីតំណាងសហភាពអឺរ៉ុប លោក Bagas Hapsoro អគ្គលេខាធិការរងអាស៊ាន និង ឯកឧត្តម **សក់ សេដ្ឋា** រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃនៃប្រទេសកម្ពុជា។

Co-funded by the European Union.

The conference is a joint venture of two European funded projects 'Supporting Decentralization in Developing Countries' and the 'Partnership for Democratic Local Governance in Southeast Asia' project (www.DELGOSEA.eu), both under the umbrella of UCLG ASPAC, UCLG as well as Konrad-Adenauer-Stiftung.

PRESS RELEASE

សិក្ខាសាលាត្រូវបែងចែកជាពីរផ្នែក។ សិក្ខាសាលានឹងកំណត់មូលដ្ឋានគ្រឹះក្នុងការរៀបចំសេចក្តីប្រកាសរួមពីអភិបាលកិច្ចមូលដ្ឋាន និងបង្ហាញពីកិច្ចសហការក្នុងតំបន់ពីការងារអភិបាលកិច្ចល្អនៅមូលដ្ឋានជាមួយអ្នកពាក់ព័ន្ធ។ សិក្ខាសាលាក៏នឹងផ្តោតជាពិសេសផងដែរលើការគ្រប់គ្រងនិងកាត់បន្ថយគ្រោះមហន្តរាយ ក្នុងក្របខ័ណ្ឌនៃការប្រែប្រួលអាកាសធាតុ និងការផ្តល់ហិរញ្ញវត្ថុដល់កម្មវិធីអភិវឌ្ឍន៍សេដ្ឋកិច្ចទីក្រុងនិងហេដ្ឋារចនាសម្ព័ន្ធ។

ផ្នែកទី១នៃសិក្ខាសាលាផ្តោតលើការធ្វើបទបង្ហាញពីការរកឃើញនៃការរៀបចំអនុសាសន៍ផ្នែកគោលនយោបាយ ដែលគម្រោងបានកំណត់។ មូលដ្ឋាននៃអនុសាសន៍ទាំងនេះគឺជាការសិក្សាថ្នាក់តំបន់ពីវិមជ្ឈការ នៃគម្រោង "គាំទ្រវិមជ្ឈការនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍" ដែលអនុវត្តដោយ UCLG ASPAC និងជាបទពិសោធន៍ជាក់ស្តែងនៃការផ្ទេរបទពិសោធន៍ល្អពីគម្រោងអភិបាលកិច្ចមូលដ្ឋាននៅអាស៊ីអាគ្នេយ៍នៃបណ្តាញ DELGOSEA ។

ផ្នែកទី២នៃសិក្ខាសាលានឹងផ្តោតលើការពិភាក្សាពីកិច្ចសហការថ្នាក់តំបន់ និងកិច្ចពិភាក្សាលើបញ្ហានិរន្តរភាព។ គោលបំណងនៃផ្នែកទី២នេះមានគោលបំណងពង្រឹងបណ្តាញអាជ្ញាធរមូលដ្ឋានជាមួយអង្គការអន្តរជាតិនិងអង្គការក្នុងតំបន់ និងកសាងទំនាក់ទំនងជិតស្និទ្ធរវាងអាជ្ញាធរមូលដ្ឋាន អង្គការសង្គមស៊ីវិលនិងសាកលវិទ្យាល័យ។ សិក្ខាសាលានឹងបញ្ចប់ជាមួយនឹងសេចក្តីប្រកាសជា គោលនយោបាយ និងរបៀបវារៈស្តីពី ការធានាបានអភិបាលកិច្ចមូលដ្ឋាន ដែលមាននិរន្តភាពតាមរយៈអភិក្រម ពហុអ្នកពាក់ព័ន្ធសម្រាប់តំបន់អាស៊ាន។

សម្រាប់ព័ត៌មានបន្ថែមពីលទ្ធផលនៃអង្គសិក្ខាសាលា សូមមើលគេហទំព័រ

Co-funded by the European Union.

The conference is a joint venture of two European funded projects 'Supporting Decentralization in Developing Countries' and the 'Partnership for Democratic Local Governance in Southeast Asia' project (www.DELGOSEA.eu), both under the umbrella of UCLG ASPAC, UCLG as well as Konrad-Adenauer-Stiftung.

www.uclg-aspac.org www.DELGOSEA.eu

Co-funded by the European Union.

The conference is a joint venture of two European funded projects ‘Supporting Decentralization in Developing Countries’ and the ‘Partnership for Democratic Local Governance in Southeast Asia’ project (www.DELGOSEA.eu), both under the umbrella of UCLG ASPAC, UCLG as well as Konrad-Adenauer-Stiftung.